Ministry of Labour and Vocational Training




# សន្និសីទថ្នាក់ជាតិ ស្តីពី សេដ្ឋកិច្ចការងារ ឆ្នាំ២០២៤

## ការងើបឡើងវិញនៃសេដ្ឋកិច្ច និងការងារ និងដំណើរឆ្ពោះទៅកាន់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច

UNDP | International Labour Organization | DEY DECENT EMPLOYMENT FOR YOUTH IN CAMBODIA | Schweizerische Eidgenossenschaft Confédération suisse Confederazione Svizzera Confederaziun svizra Swiss Agency for Development and Cooperation SDC | TAFTAC | CGTI

សណ្ឋាគារ សូហ្វីតែល ភ្នំពេញភូគីត្រា

ថ្ងៃទី១១-១២ ខែធ្នូ ឆ្នាំ២០២៤

# មាតិកា





១. សារតារ

២. គោលបំណង

៣. របៀបវារៈ

៤. ថ្ងៃទី១

៥. ថ្ងៃទី២

# ១. សាវតារ

## ១. សាវតារ

ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០២៤-២០២៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងរៀបចំសន្និសីទថ្នាក់ជាតិ ស្តីពីសេដ្ឋកិច្ចការងារប្រចាំឆ្នាំ ដែលសន្និសីទនេះនឹងក្លាយជាព្រឹត្តិការណ៍សំខាន់មួយ ដើម្បីជជែកពិភាក្សាអំពីនិន្នាការក្នុងតំបន់ ក៏ដូចជាកម្ពុជា ព្រមទាំងបញ្ហាប្រឈម និងដំណោះស្រាយនានា ដើម្បីធ្វើឱ្យទីផ្សារការងារកម្ពុជា កាន់តែមានភាពប្រសើរឡើង ស្របតាមបរិបទនៃការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច។ សម្រាប់ឆ្នាំ២០២៤នេះ សន្និសីទថ្នាក់ជាតិ ស្តីពី សេដ្ឋកិច្ចការងារ នឹងប្រព្រឹត្តទៅក្រោមប្រធានបទ «ការងើបឡើងវិញនៃសេដ្ឋកិច្ច និងការងារ និងដំណើរឆ្ពោះទៅកាន់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច» ដែលនឹងមានការចូលរួមពីអ្នកជំនាញ អ្នកតាក់តែងគោលនយោបាយ តំណាងវិស័យ ឯកជន សហជីព និងអ្នកសិក្សាស្រាវជ្រាវក្នុងតំបន់ ដើម្បីស្វែងយល់ពីនិន្នាការទីផ្សារការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងតំបន់ ក៏ដូចជាកម្ពុជា ព្រមទាំងស្វែងយល់ពីបញ្ហាប្រឈមសំខាន់ៗ ដើម្បីអាចដាក់ចេញនូវជម្រើសគោលនយោបាយសម្រាប់ដោះស្រាយ និងបង្ហាញពីឱកាសដែលកំពុងកើតមាននៅក្នុងទីផ្សារការងារ ខណៈពេលដែលកម្ពុជាត្រៀមខ្លួនក្នុងការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDC)។

ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច កម្ពុជានឹងជួបប្រទះទាំងបញ្ហាប្រឈម និងឱកាសដែលចាំបាច់តម្រូវឱ្យមានការប្រុងប្រយ័ត្នដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន។ ការពង្រឹងគោលនយោបាយមុខរបរ ឱ្យស្របគ្នាទៅនឹងតម្រូវការទីផ្សារការងារ និងការវិវត្តនៃសេដ្ឋកិច្ច ជាការចាំបាច់សម្រាប់ការបង្កើត និងបង្កើនឱកាសការងារ ដែលមានគុណភាព ដើម្បីជួយគាំទ្រទាំងកម្មករនិយោជិត ក៏ដូចជាអាជីវកម្មរបស់និយោជក។ ដូចគ្នានេះដែរ ការវិនិយោគបន្ថែមលើការអភិវឌ្ឍជំនាញនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការកសាងកម្លាំងពលកម្ម ដែលអាចសម្របខ្លួនទៅនឹងការផ្លាស់ប្តូរនៃតម្រូវការឧស្សាហកម្ម ក៏ដូចជាភាពធន់នៃសេដ្ឋកិច្ច។ ជាពិសេស ការពង្រីកកម្មវិធីអភិវឌ្ឍន៍ជំនាញ សម្រាប់យុវជន ស្ត្រី និងក្រុមជនងាយរងគ្រោះ នឹងជួយធានាថាកម្លាំង ពលកម្មកម្ពុជាមានជំនាញ សមត្ថភាព និងគុណវុឌ្ឍិគ្រប់គ្រាន់ សម្រាប់បម្រើការងារក្នុងសកម្មភាពសេដ្ឋកិច្ច ដែលមានស្រាប់ និងសកម្មភាពសេដ្ឋកិច្ចថ្មីៗមួយចំនួនទៀត ដែលបាននិងកំពុងលេចឡើង។ បន្ថែមលើនេះ ប្រព័ន្ធគាំពារសង្គមដែលរឹងមាំ និងការពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គម ដើរតួនាទីសំខាន់ក្នុងការផ្តល់ជូនកម្មករនិយោជិត និងគ្រួសារនូវសំណាញ់សុវត្ថិភាពធានាស្ថិរភាពប្រាក់ចំណូល និងកាត់បន្ថយភាពងាយរងគ្រោះ។ ប្រព័ន្ធគាំពារសង្គម ដែលគ្រប់ជ្រុងជ្រោយ ទាំងផ្នែកគ្រោះថ្នាក់ការងារ ថែទាំសុខភាព និកម្មភាព និងប្រាក់សោធន ពិតជាមានសារសំខាន់ក្នុងការកាត់បន្ថយបញ្ហាប្រឈមនានា ដែលកម្មករនិយោជិតជួបប្រទះ ស្របពេលនៃការផ្លាស់ប្តូរនៃរចនាសម្ព័ន្ធផ្នែកសេដ្ឋកិច្ច ក៏ដូចជាចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រផងដែរ។ បន្ថែមលើនេះ របបសន្តិសុខសង្គម គឺជាធាតុសំខាន់មួយ នៃស្ថាប័នទីផ្សារការងារដែលរួមចំណែករក្សាស្ថិរភាពសេដ្ឋកិច្ច តាមរយៈការលើកកម្ពស់សន្តិសុខប្រាក់ចំណូល បង្កើនភាពធន់ និងលើកកម្ពស់ភាពបទបែនក្នុងទីផ្សារការងារ។

# ២. គោលបំណង

## ២. គោលបំណង

សន្និសីទនេះមានគោលបំណងក្នុងការជំរុញកិច្ចសហការ ការផ្លាស់ប្តូរចំណេះដឹង និងនវានុវត្តន៍ ការស្វែងយល់ពីបញ្ហាប្រឈម និងឱកាសក្នុងការធ្វើឱ្យប្រសើរឡើងនៃទីផ្សារការងារ តាមរយៈកិច្ចពិភាក្សា និងការចែករំលែកចំណេះដឹង។ ក្នុងសន្និសីទនេះ អ្នកចូលរួមនឹងទទួលបាននូវចំណេះដឹងថ្មីៗ ក៏ដូចជាផ្តល់ធាតុចូលបន្ថែមដល់អ្នកតាក់តែងគោលនយោបាយ ដើម្បីដាក់ចេញនូវអន្តរាគមន៍នានាសម្រាប់ទីផ្សារការងារនៅកម្ពុជា ពង្រឹងគោលនយោបាយមុខរបរ ដែលគិតគូរបន្ថែមលើការអភិវឌ្ឍជំនាញ និងប្រព័ន្ធគាំពារសង្គម ដើម្បីកម្ពុជាឆ្ពោះទៅកាន់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចនាពេលដ៏ខ្លីខាងមុខ។

គោលបំណងសំខាន់ៗ៖

**01** ប្រមូលផ្តុំអ្នកជំនាញក្នុងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ មកពីស្ថាប័នផ្សេងគ្នា ដើម្បីចែករំលែកនូវនិន្នាការថ្មីៗ ផ្តល់មតិយោបល់ ដើម្បីធ្វើឱ្យទីផ្សារការងារនៅកម្ពុជាកាន់តែប្រសើរ ឡើងព្រមទាំងបង្ហាញពីផលជះពីការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា។

**02** ចែករំលែកការយល់ដឹង និងការអនុវត្តល្អៗពាក់ព័ន្ធនឹងការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ពីតំណាងវិស័យឯកជន អ្នកតាក់តែងគោលនយោបាយ បញ្ញវន្ត និងអ្នកសិក្សាស្រាវជ្រាវផ្សេងទៀត។

**03** ជំរុញការពិភាក្សា និងផ្តល់ធាតុចូលជាយុទ្ធសាស្ត្រ ដើម្បីធានាថាកម្លាំងពលកម្មកម្ពុជា ត្រូវបានបំពេញតាមតម្រូវការនៃយុគសម័យឌីជីថល និងបរិការណ៍នៃការប្រែប្រួលស្ថានភាពសេដ្ឋកិច្ច និងសង្គម។

**04** ជំរុញភាពជាដៃគូ និងនវានុវត្តន៍ ដែលគាំទ្រការផ្លាស់ប្តូរសេដ្ឋកិច្ច និងទីផ្សារការងារ។

# ៣. របៀបវារៈ

## ថ្ងៃទី១

| | |
|---|---|
| ៨:០០ – ៨:៣០ | ការចុះឈ្មោះអ្នកចូលរួម |
| ៨:៣០ – ១០:០០ | ចំណាប់អារម្មណ៍ដោយ លោកស្រី **Alissar Chaker** តំណាងប្រចាំប្រទេសកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) នៅកម្ពុជា<br>ចំណាប់អារម្មណ៍ដោយ លោក **Oktavianto Pasaribu** នាយករង នៃក្រុមគាំទ្របច្ចេកទេសសម្រាប់ការងារសមរម្យ នៃអង្គការអន្តរជាតិខាងការងារ (ILO)<br>សុន្ទរកថាបើកដោយ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ១០:០០ – ១០: ៣០ | សម្រាកទទួលទានអាហារសម្រន់ |
| ១០:៣០ – ១២: ០០ | វគ្គទី១៖ បម្រែបម្រួលនៃទីផ្សារការងារ និងគោលនយោបាយសេដ្ឋកិច្ចក្នុងតំបន់ សម្រាប់កំណើនការងារប្រកបដោយបរិយាបន្ន<br>បទបង្ហាញ (៣០នាទី)៖<br>• ស្តីពី «បម្រែបម្រួលកម្លាំងពលកម្ម និងបញ្ហាប្រឈមនៅក្នុងតំបន់អាស៊ាន»<br>• ស្តីពី«គោលនយោបាយសេដ្ឋកិច្ចសម្រាប់កំណើនការងារ ប្រកបដោយបរិយាបន្ននៅក្នុងតំបន់អាស៊ាន»<br>កិច្ចពិភាក្សា (៦០នាទី) |
| ១២:០០ – ១៣:០០ | សម្រាកទទួលទានអាហារថ្ងៃត្រង់ |
| ១៣:០០ – ១៤: ៣០ | វគ្គទី២៖ ផែនទីបង្ហាញផ្លូវស្តីពីយុទ្ធសាស្ត្រនៃការអភិវឌ្ឍមូលធនមនុស្ស សម្រាប់ការត្រៀមខ្លួនក្នុងការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច<br>បទបង្ហាញ (៣០នាទី)៖<br>• ស្តីពី «ផលជះនៃការចាកចេញរបស់កម្ពុជាពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច លើជំនាញ និងផលិតភាព»<br>• ស្តីពី «ផលប៉ះពាល់ នៃការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច លើសង្គមសេដ្ឋកិច្ច៖ មាគ៌ាសម្រាប់ការអភិវឌ្ឍមូលធនមនុស្ស»<br>កិច្ចពិភាក្សា (៦០នាទី) |
| ១៤:៣០ – ១៥:០០ | សម្រាកទទួលទានអាហារសម្រន់ |
| ១៥:០០ – ១៦:៣០ | វគ្គទី៣៖ តួនាទីនៃគោលនយោបាយទីផ្សារការងារសកម្មក្នុងការលើកកម្ពស់សមិទ្ធផលទីផ្សារការងារ<br>បទបង្ហាញ (៣០នាទី)៖<br>• ស្តីពី «គោលនយោបាយទីផ្សារការងារសកម្ម ក្នុងការជួយគាំទ្រការបង្កើតការងារ និងភាពមានការងារធ្វើ»<br>• ស្តីពី «ការរៀបចំស្ថាប័នទីផ្សារការងារនៅកម្ពុជា»<br>កិច្ចពិភាក្សា (៦០នាទី) |

## ថ្ងៃទី២

| | |
|---|---|
| *៨:០០ – ៨:៣០* | ការចុះឈ្មោះអ្នកចូលរួម |
| *៨:៣០ – ១០:០០* | វគ្គទី៤៖ ការអភិវឌ្ឍជំនាញសម្រាប់កសាងកម្លាំងពលកម្មប្រកបដោយភាពប្រកួតប្រជែងនៅកម្ពុជា<br>បទបង្ហាញ (៣០នាទី)៖<br>• ស្តីពី «បម្រែបម្រួលទីផ្សារការងារនៅកម្ពុជា៖ តម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្ម»<br>• ស្តីពី «ការបន្សុីប្រព័ន្ធជំនាញ សម្រាប់អន្តរកាលប្រកបដោយបរិយាបន្ន និងដំណើរឆ្ពោះទៅកាន់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច»<br>កិច្ចពិភាក្សា (៦០នាទី) |
| *១០:០០ – ១០:១៥* | សម្រាកទទួលទានអាហារសម្រន់ |
| *១០:១៥ – ១១:៤៥* | វគ្គទី៥៖ ការពង្រឹងប្រព័ន្ធសន្តិសុខសង្គម ដើម្បីលើកកម្ពស់ភាពធន់ នៃទីផ្សារការងារ និងជំរុញការចូលរួមទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ<br>បទបង្ហាញ (៣០នាទី)<br>• ស្តីពី «ការអភិវឌ្ឍថ្មីៗ និងយុទ្ធសាស្ត្រក្នុងការពង្រីករបបសន្តិសុខសង្គមឆ្ពោះទៅការដាក់ឱ្យអនុវត្តរបបនិកម្មភាព»<br>• ស្តីពី «ការជំរុញការចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងការពង្រីកវិសាលភាពរបបសន្តិសុខសង្គមដើម្បីឈានទៅសម្រេចបានការងារសមរម្យនៅកម្ពុជា»<br>កិច្ចពិភាក្សា (៦០នាទី) |
| *១១:៤៥ – ១២:០០* | បូកសរុបលទ្ធផលសន្និសីទ និងសុន្ទរកថាបិទដោយ **ឯកឧត្តម គួច សុមាន** រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| *១២:០០* | ទទួលទានអាហារថ្ងៃត្រង់ |

**ចំណាំ៖ របៀបវារៈនេះអាចមានការប្រែប្រួល ប្រសិនបើមានករណីចាំបាច់*

# ៤. ថ្ងៃទី១

# ចំណាប់អារម្មណ៍



**លោកស្រី Alissar Chaker**

អ្នកតំណាងប្រចាំប្រទេសកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) នៅកម្ពុជា

លោកស្រី ALISSAR CHAKER គឺជាអ្នកតំណាងប្រចាំប្រទេសកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) នៅកម្ពុជា។ ពីមុន លោកស្រីបានកាន់តំណែងជាអ្នកគ្រប់គ្រងផ្សេងៗនៃអង្គការ UNDP នៅតាមបណ្តាប្រទេសនានាទាំងក្នុង និងក្រោយវិបត្តិនានា ព្រមទាំងឆ្លងកាត់បរិបទនៃការអភិវឌ្ឍន៍ជាច្រើនដូចជានៅប្រទេសទុយនីស៊ី (២០១៩-២០២១), ហុងឌូរ៉ាស (២០១៦-២០១៩), ស៊ីរី(២០១៣-២០១៥), មជ្ឈមណ្ឌលប្រចាំតំបន់ នៅទីក្រុងគែរ(២០១២-២០១៣) និងទីម័រខាងកើត(២០០៧-២០១២)។ លោកស្រីបានចូលបម្រើការងារឱ្យអង្គការ UNDP នៅចុងឆ្នាំ២០០៥ ក្នុងក្របខ័ណ្ឌនៃកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំសម្រាប់អ្នកជំនាញវ័យក្មេង ឬ LEAD របស់អង្គការ UNDP ហើយបានចាប់ផ្តើម អាជីពរបស់លោកស្រីជាមួយអង្គការ UNDP ជាអ្នកឯកទេសកម្មវិធីដែលត្រូវបានបញ្ជូនទៅកម្មវិធីអ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ដែលគ្រប់គ្រងដោយ UNDP នៅទីក្រុង BONN ប្រទេសអាល្លឺម៉ង់ ពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៧។ មុនពេលលោកស្រីបម្រើការងារឱ្យ UNDP លោកស្រីក៏បានធ្វើការនៅក្នុងវិស័យបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាពជាមួយវិស័យឯកជន និងអង្គការអន្តរជាតិមួយចំនួននៅក្នុងប្រទេសស្វីស មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង។ លោកស្រី ALISSAR ទទួលបានសញ្ញាបត្រអនុបណ្ឌិតចំនួនពីរគឺផ្នែកវិស្វកម្ម និងការគ្រប់គ្រងបរិស្ថានពីសាកលវិទ្យាល័យ ÉCOLE POLYTECHNIQUE FÉDÉRALE DE LAUSANNE (EPFL) ប្រទេសស្វីស និងសាកលវិទ្យាល័យ MANCHESTER នៃចក្រភពអង់គ្លេស។ លើសពីនេះ លោកស្រីចេះភាសាអារ៉ាប់ អង់គ្លេស បារាំង អេស្ប៉ាញ អាឡឺម៉ង់ អ៊ីតាលី និងព័រទុយហ្គាល់ផងដែរ។



**លោក Oktavianto Pasaribu**

នាយករង នៃក្រុមគាំទ្របច្ចេកទេសសម្រាប់ការងារសមរម្យ នៃអង្គការអន្តរជាតិខាងការងារ

លោក OKTAVIANTO PASARIBU គឺជានាយករងនៃក្រុមគាំទ្របច្ចេកទេសសម្រាប់ការងារសមរម្យ នៃអង្គការ ILO សម្រាប់អាស៊ីបូព៌ា អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក ព្រមទាំងជានាយករងការិយាល័យ ILO ប្រចាំប្រទេសថៃ កម្ពុជា និងឡាវ ចាប់តាំងពីខែសីហា ឆ្នាំ២០២៣។ លោកមានជំនាញ និងបទពិសោធន៍ជាង ២៥ឆ្នាំ ក្នុងការអភិវឌ្ឍអន្តរជាតិ នៅអាស៊ីប៉ាស៊ីហ្វិក និងមជ្ឈិមបូព៌ា។ លើសពីនេះលោកក៏ធ្លាប់ជាផ្នែកមួយ នៃក្រុមការងារគ្រប់គ្រងជាន់ខ្ពស់របស់ ILO ប្រចាំតំបន់សម្រាប់រដ្ឋអារ៉ាប់ ដោយមើលការខុសត្រូវលើ គម្រោង ១១ប្រទេស។ លោកមានជំនាញរៀបចំ អនុវត្ត និងវាយតម្លៃគម្រោងដោយផ្តោតលើស្តង់ដាការងារអន្តរជាតិ ការឆ្លើយតបនឹងវិបត្តិ, ការធ្វើចំណាកស្រុក, ការជួញដូរមនុស្ស, ការបញ្ជ្រាបយេនឌ័រ និងការលុបបំបាត់ពលកម្មកុមារជាដើម។ លោកមានបទពិសោធន៍ជាក់ស្តែងក្នុងការងារ យុវជន ស្ត្រី និងកម្មវិធី ជួយសង្គ្រោះគ្រោះមហន្តរាយ ព្រមទាំងមានការយល់ដឹងស៊ីជម្រៅលើឧបករណ៍គ្រប់គ្រងរបស់ ILO។



**ឯកឧត្តម ហេង សួរ**

រដ្ឋមន្ត្រីក្រសួងការងារ
និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សុន្ទរកថា បើក

**ឯកឧត្តម ហេង សួរ** បច្ចុប្បន្នជា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា។ បន្ថែមពីនេះ **ឯកឧត្តមរដ្ឋមន្ត្រី** ក៏ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ អស់រយៈពេលប្រមាណជាងមួយទសវត្សរ៍កន្លងមក។ ក្នុងរយៈពេលជិតពីរទសវត្សរ៍នៃការបម្រើការងារជូនរាជរដ្ឋាភិបាលកម្ពុជា **ឯកឧត្តមរដ្ឋមន្ត្រី** បានបង្កើតនូវភាពលេចធ្លោ និងចូលរួមចំណែកយ៉ាងសំខាន់ៗជាច្រើនមិនអាចបដិសេធបាន។ **ឯកឧត្តមរដ្ឋមន្ត្រី** ធ្លាប់បានបំពេញតួនាទីភារកិច្ចជានាយកខុទ្ទកាល័យ រដ្ឋលេខាធិការ ព្រមទាំងអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដោយ **ឯកឧត្តមរដ្ឋមន្ត្រី** បានចូលបម្រើការជាមន្ត្រីរាជការនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចាប់តាំងពីឆ្នាំ២០០៥ មកម្ល៉េះ។

ដោយឡែក សម្រាប់ប្រវត្តិសិក្សា **ឯកឧត្តមរដ្ឋមន្ត្រី** បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកគោលនយោបាយសារធារណៈ ជំនាញហិរញ្ញវត្ថុសាធារណៈ ពីសាកលវិទ្យាល័យ Hitotsubashi ទីក្រុងតូក្យូ ប្រទេសជប៉ុន។ ក្រៅពីតួនាទីក្នុងជួររាជរដ្ឋាភិបាល **ឯកឧត្តមរដ្ឋមន្ត្រី** ក៏បានចូលរួមចំណែកយ៉ាងក្លៀវក្លានៅក្នុងសកម្មភាពសង្គម យ៉ាងច្រើន។ **ឯកឧត្តមរដ្ឋមន្ត្រី** ក៏ជាអនុប្រធានក្រុមប្រឹក្សាភិបាលមូលនិធិអភិវឌ្ឍន៍ជំនាញ និងធ្លាប់បានកាន់តំណែងជាប្រធានសមាគមអតីតនិស្សិតខ្មែរពីប្រទេសជប៉ុន ចំនួន ២អាណត្តិជាប់គ្នា ចាប់ពីឆ្នាំ២០០៨ ដល់ ឆ្នាំ២០២១ និងធ្លាប់បានចូលរួមជាទីប្រឹក្សានៃមជ្ឈមណ្ឌលថ្នាក់តំបន់ដើម្បីអនាគតនៃការងារចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២២។ បច្ចុប្បន្ននេះ **ឯកឧត្តមរដ្ឋមន្ត្រី** ក៏នៅបន្តតួនាទីជាប្រធានសមាគមសហព័ន្ធសិស្ស-និស្សិត អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាំងពីឆ្នាំ២០១៧ មកផងដែរ។

## វគ្គទី ១៖
## “បម្រែបម្រួលនៃទីផ្សារការងារ និងគោលនយោបាយសេដ្ឋកិច្ចក្នុងតំបន់ សម្រាប់កំណើនការងារប្រកបដោយបរិយាបន្ន”

វគ្គទី១នេះ មានគោលបំណងផ្តល់នូវទិដ្ឋភាពទូទៅនៃស្ថានភាពទីផ្សារការងារនាពេលបច្ចុប្បន្ននៅតំបន់ ដោយផ្តោតលើគោលនយោបាយអភិវឌ្ឍន៍មូលធនមនុស្សក្នុងអាស៊ាន និងគោលនយោបាយការងារនៅកម្ពុជា។ វគ្គនេះក៏នឹងប្រមូលផ្តុំអ្នកជំនាញមកពីខាងរាជរដ្ឋាភិបាល និងអង្គការអន្តរជាតិ ដើម្បីពិភាក្សាអំពីនិន្នាការ និងបញ្ហាប្រឈមចុងក្រោយបំផុតនៅក្នុងទីផ្សារការងារតំបន់ ព្រមទាំងទីផ្សារការងាររបស់កម្ពុជា និងដំណោះស្រាយសម្រាប់ការលើកកម្ពស់កំណើនការងារ។

ការពិភាក្សានេះមានសារៈសំខាន់ដូចខាងក្រោម៖

- ជាវេទិកាមួយសម្រាប់អ្នកជំនាញដើម្បីវិភាគនិន្នាការចុងក្រោយបំផុត បញ្ហាប្រឈម និងឱកាសនៅក្នុងទីផ្សារការងារ នៅក្នុងតំបន់ និងនៅកម្ពុជា ដោយផ្តោតការវិភាគពីបច្ចុប្បន្នភាពនៃទីផ្សារការងារ ព្រមទាំងការដាក់ចេញគោលនយោបាយផ្អែកលើភស្តុតាង និងអន្តរាគមន៍នានាឱ្យចំគោលដៅ។
- ពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយ នូវតួនាទីសំខាន់ៗនៃសក្តានុពលទីផ្សារការងារក្នុងការសម្រេចឱ្យបាននូវការចាកចេញពីប្រទេសដែលមានការអភិវឌ្ឍតិចតួចប្រកបដោយជោគជ័យ។
- ការពិភាក្សានេះ ក៏ស្វែងរកធាតុចូលពីរាជរដ្ឋាភិបាល តំណាងអង្គការអន្តរជាតិ និងអ្នកស្រាវជ្រាវ ក្នុងន័យជំរុញឱ្យមានកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗក្នុងទីផ្សារការងារ។ ម្យ៉ាងទៀត ការពិភាក្សានេះក៏ជំរុញឱ្យមានការផ្លាស់ប្តូរចំណេះដឹង និងទស្សនៈដែលអាចនាំទៅរកដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត និងកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីលើកកម្ពស់កំណើនការងារ។
- តាមរយៈការពិភាក្សា និងបទបង្ហាញរបស់អ្នកជំនាញ ការពិភាក្សាក៏ត្រូវបានរំពឹងថានឹងបង្កើតនូវអនុសាសន៍ គោលនយោបាយមួយចំនួនដែលមានតម្លៃសម្រាប់អ្នកធ្វើគោលនយោបាយ។ ម្យ៉ាងទៀត អនុសាសន៍ទាំងនេះអាចជូនជាព័ត៌មានអំពីយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍មូលធនមនុស្ស ការបង្កើតការងារ និងការគាំពារសង្គម និងជាចុងក្រោយគាំទ្រដល់ការផ្លាស់ប្តូរប្រកបដោយជោគជ័យរបស់ប្រទេសកម្ពុជាចេញពីប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច។

### បទបង្ហាញស្តីពី៖

**«បម្រែបម្រួលកម្លាំងពលកម្ម និងបញ្ហាប្រឈមនៅក្នុងតំបន់អាស៊ាន»**



Dr. Rashesh Shrestha
សេដ្ឋកិច្ចវិទូនៃវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន និងអាស៊ីបូព៌ា



Dr. Shandre Mugan Thangavelu
ប្រធានវិទ្យាស្ថាន Jeffrey Cheah អាស៊ីអាគ្នេយ៍ នៅសាកលវិទ្យាល័យ Sunway

**«គោលនយោបាយសេដ្ឋកិច្ចសម្រាប់កំណើនការងារ ប្រកបដោយបរិយាបន្ននៅក្នុងតំបន់អាស៊ាន»**

### កិច្ចពិភាក្សា៖

**អ្នកសម្របសម្រួល**



ឯកឧត្តមបណ្ឌិត អ៊ុំ ច័ន្ទមនោ

**ទីប្រឹក្សាអម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**



ឯកឧត្តម គួច សុមាន

**រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**



Dr. Rashesh Shrestha

**សេដ្ឋកិច្ចវិទូនៃវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន និងអាស៊ីបូព៌ា**



Dr. Shandre Mugan Thangavelu

**ប្រធានវិទ្យាស្ថាន Jeffrey Cheah អាស៊ីអាគ្នេយ៍ នៅសាកលវិទ្យាល័យ Sunway**

# វាគ្មិនកិត្តិយស



**Dr. Shandre Mugan Thangavelu**
ប្រធានវិទ្យាស្ថាន Jeffrey Cheah
អាស៊ីអាគ្នេយ៍ នៅសាកលវិទ្យាល័យ Sunway

**សាស្ត្រាចារ្យ Shandre M. Thangavelu** ជាប្រធានវិទ្យាស្ថាន Jeffrey Cheah Institute for Southeast Asia និងជាអ្នកជំនាញជាន់ខ្ពស់នៅមជ្ឈមណ្ឌល Jeffrey Sachs ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព នៃសាកលវិទ្យាល័យ Sunway, ប្រទេសម៉ាឡេស៊ី។ លោកសាស្ត្រាចារ្យ ក៏បានចូលបម្រើការងារនៅសាកលវិទ្យាល័យ Adelaide នៃប្រទេសអូស្ត្រាលីផងដែរ ហើយនៅឆ្នាំ២០២១ លោកសាស្ត្រាចារ្យត្រូវបានតែងតាំងជាទីប្រឹក្សាពាណិជ្ជកម្មរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មរបស់កម្ពុជា ដោយបានទទួលមេដាយសុវត្ថារាជថ្នាក់ធិបឌិន្ទ នៅក្នុងឆ្នាំ២០២៣ ក្នុងកិច្ចរួមចំណែកជំរុញកំណើនពាណិជ្ជកម្ម និងសេដ្ឋកិច្ចរបស់កម្ពុជា។ លោកសាស្ត្រាចារ្យ ជាអ្នកជំនាញផ្នែកធនធានមនុស្ស ការវិនិយោគផ្ទាល់ពីបរទេស និងសមាហរណកម្មអាស៊ាន។ លោកសាស្ត្រាចារ្យមានស្នាដៃជាច្រើន និងជាអ្នកនិពន្ធសៀវភៅមួយចំនួនដូចជា សៀវភៅណែនាំ ស្តីពីសមាហរណកម្មសេដ្ឋកិច្ចអាស៊ីបូព៌ា។ លោកសាស្ត្រាចារ្យ បានទទួលសញ្ញាបត្រពីសាកលវិទ្យាល័យ Queen's University ប្រទេសកាណាដា។



**Dr. Rashesh Shrestha**
សេដ្ឋកិច្ចវិទូនៃវិទ្យាស្ថាន
ស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន និងអាស៊ីបូព៌ា

**លោកបណ្ឌិត Rashesh** ជាសេដ្ឋវិទូនៅវិទ្យាស្ថានសិក្សាស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា ( ERIA ) ដែលធ្វើការស្រាវជ្រាវលើទីផ្សារការងារ ការអភិវឌ្ឍសេដ្ឋកិច្ច និងការវិនិយោគមូលធនមនុស្ស។ នៅ ERIA លោកបណ្ឌិតធ្វើការសិក្សាស្រាវជ្រាវ និងដឹកនាំគម្រោងស្រាវជ្រាវតម្រង់ទិសគោលនយោបាយលើប្រធានបទជាច្រើនរួមមាន ៖ មូលធនមនុស្ស ការអប់រំ ខ្សែច្រវ៉ាក់តម្លៃសកលពាណិជ្ជកម្ម និងបរិយាបន្នហិរញ្ញវត្ថុ។ មុនពេលចូលរួមជាមួយ ERIA លោកបណ្ឌិតគឺជាជំនួយការសាស្ត្រាចារ្យនៅសាកលវិទ្យាល័យជាតិអូស្ត្រាលី លោកបណ្ឌិតបានទទួលសញ្ញាបត្រកម្រិតបណ្ឌិតផ្នែកកសិកម្ម និងសេដ្ឋកិច្ចអនុវត្ត ពីសាកលវិទ្យាល័យ Wisconsin-Madison។



**ឯកឧត្តម គួច សុមាន**
រដ្ឋលេខាធិការ
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ឯកឧត្តម គួច សុមាន** បានចាប់ផ្តើមបម្រើការងារនៅក្នុងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងឆ្នាំ២០១២។ ឯកឧត្តមធ្លាប់មានតួនាទីជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា, អនុប្រធាននៃទីភ្នាក់ងារជាតិមុខរបរ និងការងារ និងជាទីប្រឹក្សាអមក្រសួងផងដែរ។ បច្ចុប្បន្ន ឯកឧត្តមមានតួនាទីជារដ្ឋលេខាធិការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ឯកឧត្តម បានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍ និងលើកកម្ពស់សេវាការងារសាធារណៈ, ប្រព័ន្ធព័ត៌មានទីផ្សារការងារ, សន្តិសុខសង្គម, ប្រាក់ឈ្នួលអប្បបរមានៅក្នុងប្រទេសកម្ពុជា និងគោលនយោបាយជាតិមួយចំនួនផងដែរ។ ឯកឧត្តម បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែក Applied Labour Economics for Development ពីប្រទេសបារាំង និងអ៊ីតាលី, ផ្នែកគ្រប់គ្រង ពីប្រទេសបារាំង និងកំពុងបន្តការសិក្សាថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យណាហ្គូយ៉ា ( Nagoya University ) ប្រទេសជប៉ុន លើជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍។



**ឯកឧត្តមបណ្ឌិត អ៊ុំ ច័ន្ទមនោ**
ទីប្រឹក្សាអម
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ឯកឧត្តមបណ្ឌិត អ៊ុំ ច័ន្ទមនោ** ជាទីប្រឹក្សាអមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ឯកឧត្តមបណ្ឌិត ធ្លាប់ជាអ្នកដឹកនាំ និងជាអ្នកផ្តល់ប្រឹក្សាលើគម្រោងស្រាវជ្រាវជាច្រើនសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ដូចជា Australian Award Cambodia, CAVAC CARITAS Australia , DFAT, JICA, IOM, UNOPS, និង USAID ជាដើម។ ឯកឧត្តមបណ្ឌិត មានបទពិសោធន៍ និងចំណាប់អារម្មណ៍ក្នុងការស្រាវជ្រាវពាក់ព័ន្ធនឹងសេដ្ឋកិច្ចការងារ កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ ឥណទានខ្នាតតូច ការធ្វើចំណាកស្រុក និងប្រាក់បញ្ញើពីបរទេស។

## វគ្គទី ២៖
## "ផែនទីបង្ហាញផ្លូវស្តីពីយុទ្ធសាស្ត្រនៃការអភិវឌ្ឍមូលធនមនុស្ស សម្រាប់ការត្រៀមខ្លួនក្នុងការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច"

វគ្គទី២នេះ មានគោលបំណងពិភាក្សាពីយុទ្ធសាស្ត្រដើម្បីអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា តាមរយៈការពង្រឹងជំនាញការងារ ដោយបង្ហាញពីបញ្ហា និងឱកាសសម្រាប់ការកសាងកម្លាំងពលកម្មដែលមានសមត្ថភាពដែលអាចប្រកួតប្រជែងនូវតម្រូវការរបស់សេដ្ឋកិច្ចសកម្ម និងជាពិសេសសម្រាប់ការចាកចេញពីក្រុមប្រទេសដែលមានការអភិវឌ្ឍតិចតួច។ វគ្គនេះ នឹងអញ្ជើញភាគីពាក់ព័ន្ធឱ្យធ្វើការពិភាក្សាអំពីការកែប្រែគោលនយោបាយ ការចូលរួមជាមួយឧស្សាហកម្ម និងវិធីសាស្ត្រអប់រំ ដើម្បីជំរុញការអភិវឌ្ឍកម្លាំងពលកម្មដោយចីរភាព។

ការអភិវឌ្ឍកម្លាំងពលកម្ម ដែលអាចឆ្លើយតបនឹងការប្រកួតប្រជែងក្នុងសេដ្ឋកិច្ចពិភពលោក ធានាឱ្យកម្ពុជាអភិវឌ្ឍប្រកបដោយចីរភាពរួមមាន៖

- លើកកម្ពស់ការចែករំលែកអំពីគម្លាតជំនាញក្នុងវិស័យសំខាន់ៗ
- កំណត់គោលនយោបាយ និងភាពជាដៃគូដែលចាំបាច់សម្រាប់ការអភិវឌ្ឍជំនាញដ៏មានប្រសិទ្ធភាព
- ពិនិត្យមើលតួនាទីរបស់ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការបង្កើនសមត្ថភាពកម្លាំងពលកម្ម

### បទបង្ហាញស្តីពី៖



**ឯកឧត្តម ប្រុញ សុភាណា**
អគ្គលេខាធិការ នៃ អ.ក.ជ.ប.អ.
នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**«ផលជះនៃការចាកចេញរបស់កម្ពុជាពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច លើជំនាញ និងផលិតភាព»**



**Dr. Iván González de Alba**
សេដ្ឋវិទូ នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ
ប្រចាំប្រទេសកម្ពុជា

**«ផលប៉ះពាល់ នៃការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច លើសង្គមសេដ្ឋកិច្ច៖ មាគ៌ាសម្រាប់ការអភិវឌ្ឍមូលធនមនុស្ស»**

### កិច្ចពិភាក្សា៖

**អ្នកសម្របសម្រួល**



ឯកឧត្តមបណ្ឌិត ទ្រី សុផល

**ទីប្រឹក្សាអម**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**



ឯកឧត្តម ប្រុញ សុភាណា

**អគ្គលេខាធិការ នៃ អ.ក.ជ.ប.អ.**
**នៃក្រសួងការងារ**
**និងបណ្តុះបណ្តាលវិជ្ជាជីវៈ**



Dr. Iván González de Alba

**សេដ្ឋវិទូ នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**
**ប្រចាំប្រទេសកម្ពុជា**



លោកបណ្ឌិត អ៊ុំ សុធា

**ទីប្រឹក្សាជាន់ខ្ពស់ផ្នែកគោលនយោបាយ**
**នៃកម្មវិធីភាពជាដៃគូ កម្ពុជា-អូស្ត្រាលី**
**សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយ**
**ភាពធន់(CAPRED)**



ឯកឧត្តម សុខន តារាពី

**នាយករងប្រតិបត្តិ**
**មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា**

# វាគ្មិនកិត្តិយស



**ឯកឧត្តម ប្រុញ សុភាណា**
អគ្គលេខាធិការ នៃ អ.ក.ជ.ប.អ.
នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ឯកឧត្តម ប្រុញ សុភាណា** គឺជាអ្នកជំនាញផ្នែកគោលនយោបាយសាធារណៈ និងសិក្សាស្រាវជ្រាវ ព្រមទាំង មានបទពិសោធន៍ក្នុងវិស័យអភិវឌ្ឍជំនាញ និងទីផ្សារការងារ។ ក្នុងឋានៈជា អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តមដឹកនាំការស្រាវជ្រាវប្រធានបទនានាអំពីប្រាក់ឈ្នួល ទីផ្សារការងារ និងស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ដើម្បីគាំទ្រដល់ការអភិវឌ្ឍគោលនយោបាយពាក់ព័ន្ធ។ ឯកឧត្តមទទួលបានសញ្ញាបត្រអនុបណ្ឌិតចំនួនពីរគឺ ផ្នែកគោលនយោបាយសាធារណៈ និងការគ្រប់គ្រងការអភិវឌ្ឍ។ ប្រធានបទស្រាវជ្រាវ ជាស្នាដៃរបស់ឯកឧត្តម រួមមានដូចជា គោលនយោបាយទីផ្សារការងារសកម្ម និងនិន្នាការប្រាក់ឈ្នួលនៅកម្ពុជាជាដើម។ ជាមួយនឹងបទពិសោធន៍យ៉ាងទូលំទូលាយក្នុងការសម្របសម្រួលគោលនយោបាយ និងការអភិវឌ្ឍជំនាញ ឯកឧត្តម បានចូលរួមចំណែកជាច្រើនក្នុងការជំរុញការអភិវឌ្ឍធនធានមនុស្ស និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ននៅកម្ពុជា។



**Dr. Iván González de Alba**
សេដ្ឋវិទូ នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ
ប្រចាំប្រទេសកម្ពុជា

**លោកបណ្ឌិត Iván** ជាសេដ្ឋវិទូជាន់ខ្ពស់នៃ អង្គការ UNDP ប្រចាំនៅកម្ពុជាតាំងពីខែសីហា ឆ្នាំ២០២០ ដោយលោកបណ្ឌិតដឹកនាំ និងត្រួតពិនិត្យការងារលើ ពហុវិមាត្រនៃភាពក្រីក្រ និងភាពងាយរងគ្រោះ កិច្ចគាំពារសង្គមដើម្បីបញ្ចប់ភាពទីទាល់ក្រ ការវាយតម្លៃផលប៉ះពាល់ គំរូម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយសេដ្ឋកិច្ច ហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ និងជួយដល់ដំណើរនៃការបញ្ចប់ភាពក្រីក្ររបស់ប្រទេសអភិវឌ្ឍន៍តិចតួច។ លោកបណ្ឌិតបានសហការជាមួយសមភាគីសំខាន់ៗរបស់រាជរដ្ឋាភិបាល រួមមាន៖ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា និងក្រសួងផែនការ ព្រមទាំងទីភ្នាក់ងារ និងដៃគូអភិវឌ្ឍន៍ដទៃទៀតរបស់អង្គការសហប្រជាជាតិ។ មុននឹងចូលរួមជាមួយ ការិយាល័យប្រចាំប្រទេសកម្ពុជា លោកបណ្ឌិត បានបម្រើការជាទីប្រឹក្សាប្រចាំតំបន់ស្តីពី ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅមជ្ឈមណ្ឌលប្រចាំតំបន់របស់អង្គការ UNDP នៅអាមេរិកឡាទីន និងការាបៀន ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២០ ដែលគាំទ្រដល់ការិយាល័យប្រទេសក្នុងតំបន់លើការធ្វើសមាហរណកម្ម និងកំណើនរួមបញ្ចូលនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ លោកបណ្ឌិតក៏បានធ្វើការជាទីប្រឹក្សារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍សង្គម និងអភិវឌ្ឍន៍ទីក្រុងផងដែរ ហើយលោកបណ្ឌិតក៏ជានាយកផ្នែកវិភាគសេដ្ឋកិច្ច នៅក្រសួងទេសចរណ៍ក្នុងប្រទេសកំណើតរបស់លោកបណ្ឌិតនៅប្រទេសម៉ិកស៊ិក។ លោកបណ្ឌិតគឺជាសេដ្ឋវិទូ ដែលទទួលបានការបណ្តុះបណ្តាល និងសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច គោលនយោបាយសាធារណៈ ក៏ដូចជាសញ្ញាប័ត្របណ្ឌិត ពីសាកលវិទ្យាល័យ Oxford ក្នុងផ្នែកការអភិវឌ្ឍអន្តរជាតិ ដែលជាកន្លែងដែលលោកបម្រើការងារនៅ OPHI។



**លោកបណ្ឌិត អ៊ុំ សុធា**
ទីប្រឹក្សាជាន់ខ្ពស់ផ្នែកគោលនយោបាយ
នៃកម្មវិធីភាពជាដៃគូ កម្ពុជា-អូស្ត្រាលីសម្រាប់
ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយភាពធន់(CAPRED)

**លោកបណ្ឌិត អ៊ុំ សុធា** ជាទីប្រឹក្សាគោលនយោបាយជាន់ខ្ពស់នៃកម្មវិធីភាពជាដៃគូ កម្ពុជា អូស្ត្រាលីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED) ដែលជាកម្មវិធីសហប្រតិបត្តិការទ្វេភាគីដ៏សំខាន់នៃរដ្ឋាភិបាលអូស្ត្រាលីសម្រាប់ប្រទេសកម្ពុជា។ លោកបណ្ឌិតធ្លាប់ធ្វើជាទីប្រឹក្សានៅបណ្តាអង្គការជាតិ និងអន្តរជាតិនានា ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក (World Bank) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ជាដើម។ លោកបណ្ឌិតក៏ធ្លាប់បង្រៀន និងស្រាវជ្រាវនៅបណ្តាសាកលវិទ្យាល័យនានាក្នុងប្រទេសកម្ពុជា សិង្ហបុរី អូស្ត្រាលី និងកោះហ្វីជី បន្ទាប់ពីបានបម្រើការ ៦ឆ្នាំជាសេដ្ឋវិទូនៅវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ីអាគ្នេយ៍ និងអាស៊ីបូព៌ា (ERIA) ទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី។ លោកបណ្ឌិតទទួលបានសញ្ញាបត្រថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Monash ប្រទេសអូស្ត្រាលី និងអនុបណ្ឌិតសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Kobe ប្រទេសជប៉ុន។



**ឯកឧត្តម សុខន តារាពី**
នាយករងប្រតិបត្តិ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា

**ឯកឧត្តម សុខន តារាពី** បច្ចុប្បន្នជាជំនួយការប្រធានគណៈកម្មការសុខាភិបាល កិច្ចការសង្គម អតីតយុទ្ធជន ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី នៃរដ្ឋសភា និងជាអនុប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ នៃគណៈកម្មាធិការកណ្តាលសហភាពសហព័ន្ធយុវជនកម្ពុជាផងដែរ។ មុនពេលចូលបម្រើការងារនៅមជ្ឈមណ្ឌលស៊ីឌីស៊ី ឯកឧត្តមបានបម្រើការជាអនុប្រធានទីមួយនៃសមាគមសាលាត្រាជូ ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨។ ឯកឧត្តម បន្តការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងដែនដី និងសហគ្រាស ដោយផ្តោតលើ "ទំនាក់ទំនងសេដ្ឋកិច្ច អឺរ៉ុប-អាស៊ី" នៃសាកលវិទ្យាល័យ Rennes II និងសាកលវិទ្យាល័យពាណិជ្ជកម្មក្រៅប្រទេសនៅទីក្រុងហាណូយ ប្រទេសវៀតណាម។ បន្ទាប់មក ឯកឧត្តមបានសិក្សាថ្នាក់អនុបណ្ឌិត ច្បាប់ពាណិជ្ជកម្មអន្តរជាតិ ពីសាកលវិទ្យាល័យ Westminster ទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស។ ក្រៅពីជំនាញខាងលើ ឯកឧត្តមចាប់អារម្មណ៍លើច្បាប់សាធារណៈ ស្ថាប័ននយោបាយ ទំនាក់ទំនងអន្តរជាតិ និងសេដ្ឋកិច្ចនយោបាយ។



**ឯកឧត្តមបណ្ឌិត ទ្រី សុផល**
ទីប្រឹក្សាអម
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ឯកឧត្តមបណ្ឌិត ទ្រី សុផល** បានទទួលបណ្ឌិតវិស្វកម្មពីសាកលវិទ្យាល័យក្យូតូ ប្រទេសជប៉ុន ថ្នាក់អនុបណ្ឌិត ពីសាកលវិទ្យាល័យជាតិក្យុងប៊ុក សាធារណរដ្ឋកូរ៉េខាងត្បូង និងវិស្វករពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ មុនពេលចូលបម្រើការជាទីប្រឹក្សានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តមបណ្ឌិត បានធ្វើការជាអ្នកស្រាវជ្រាវ នៅសាកលវិទ្យាល័យក្យូតូ រយៈពេលពីរឆ្នាំ និងនៅសាកលវិទ្យាល័យបច្ចេកវិទ្យាណានយ៉ាង (NTU) ប្រទេសសិង្ហបុរីរយៈពេលមួយឆ្នាំ។ បន្ថែមពីលើប្រវត្តិស្រាវជ្រាវទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងវិស្វកម្មគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិ ឯកឧត្តមបណ្ឌិតកំពុងស្រាវជ្រាវលើប្រធានបទស្តីពី មូលធនមនុស្ស, ទីផ្សារការងារ, បញ្ញាសិប្បនិមិត្ត, Machine learning និងការប្រើប្រាស់ទិន្នន័យផ្កាយរណបជាដើម។ ឯកឧត្តមបណ្ឌិត ក៏បានបោះពុម្ពអត្ថបទស្រាវជ្រាវ ជាង ២០អត្ថបទ។

## វគ្គទី៣៖
## តួនាទីនៃគោលនយោបាយទីផ្សារការងារសកម្ម ក្នុងការលើកកម្ពស់សមិទ្ធផលទីផ្សារការងារ

គោលបំណងចម្បងសម្រាប់វគ្គទី៣នេះគឺ ដើម្បីពិភាក្សាអំពីតួនាទីសំខាន់ៗនៃគោលនយោបាយទីផ្សារការងារសកម្ម (ALMP) ក្នុងការបង្កើតការងារ និងបង្កើនកម្លាំងពលកម្មជំនាញ ក៏ដូចជាការពង្រឹងលទ្ធភាពការងារនៅក្នុងប្រទេសកម្ពុជា ស្របពេលដែលប្រទេសកម្ពុជាត្រៀមខ្លួនក្នុងការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDC)។ វាគ្មិនជាតិនិងអន្តរជាតិ នឹងផ្តល់នូវការពិភាក្សារួមគ្នា អំពីតួនាទីរបស់សេវាការងារសាធារណៈ(PES)ក្នុងការសម្របសម្រួលមុខងារទីផ្សារការងារ និងការលើកកម្ពស់ឱកាសការងារ ក៏ដូចជាយុទ្ធសាស្ត្រផ្សេងៗក្នុងការអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម ដែលអាចគាំទ្រដល់កំណើនសេដ្ឋកិច្ចកម្ពុជា។

ការពិភាក្សានេះមានសារៈសំខាន់ដូចខាងក្រោម៖

- បង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍគោលនយោបាយការងារសកម្ម ដើម្បីជំរុញការបង្កើតការងារ និងដោះស្រាយគម្លាតជំនាញ ជាពិសេសសម្រាប់ក្រុមងាយរងគ្រោះ។
- ពង្រឹងតួនាទីនៃសេវាការងារសាធារណៈ (PES) ដោយលើកកម្ពស់លទ្ធភាពនៃការចូលទៅកាន់ទីផ្សារការងារ ឱ្យកាន់តែទូលំទូលាយ និងការសម្របខ្លួនទៅនឹងបញ្ហាប្រឈមនៃការផ្លាស់ប្តូរសេដ្ឋកិច្ច។
- រៀបចំកម្លាំងពលកម្មរបស់កម្ពុជាសម្រាប់តម្រូវការនៃឧស្សាហកម្មដែលកំពុងរីកចម្រើនដោយដោះស្រាយគម្លាត ជំនាញបច្ចុប្បន្ន និងការលើកកម្ពស់គំនិតផ្តួចផ្តើមបង្កើនជំនាញ។

### បទបង្ហាញស្តីពី៖

«គោលនយោបាយទីផ្សារការងារសកម្មក្នុងការជួយគាំទ្រការបង្កើតការងារ និងភាពមានការងារធ្វើ»



**លោកស្រី Mastumoto Makiko**
អ្នកជំនាញការផ្នែកមុខរបរ និងការងារនៃ
អង្គការអន្តរជាតិខាងការងារ ILO

«ការរៀបចំស្ថាប័នទីផ្សារការងារនៅកម្ពុជា»



**លោកបណ្ឌិត គី សេរីវុធ**
អគ្គលេខាធិការរង នៃ អ.ក.ជ.ប.អ.
នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

### កិច្ចពិភាក្សា៖

**អ្នកសម្របសម្រួល**



លោក Shakeel Ahmad
**អ្នកតំណាងរងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំប្រទេសកម្ពុជា**



លោកបណ្ឌិត គី សេរីវុធ
**អគ្គលេខាធិការរង នៃ អ.ក.ជ.ប.អ. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**



លោកសុខ ឡោ
**តំណាងមកពីសហព័ន្ធនិយោជក និងសមាគមពាណិជកម្មកម្ពុជា**



លោកស្រី Mastumoto Makiko
**អ្នកជំនាញការផ្នែកមុខរបរ និងការងារនៃ អង្គការអន្តរជាតិខាងការងារ ILO**



Dr. Abla Safir
**សេដ្ឋវិទូជាន់ខ្ពស់ នៃធនាគារពិភពលោក**

# ទាក្ខិនកិត្តិយស



**លោកបណ្ឌិត គី សេរីវុធ**
អគ្គលេខាធិការរង នៃ អ.ក.ជ.ប.អ.
នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**លោកបណ្ឌិត គី សេរីវុធ** ជាសេដ្ឋវិទូការងារ និងជាអ្នកជំនាញស្រាវជ្រាវ ដែលមានឯកទេសលើការអភិវឌ្ឍជំនាញ និងការវិភាគទីផ្សារការងារ។ ក្នុងនាមជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមានៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោកបណ្ឌិតបានដឹកនាំការស្រាវជ្រាវលើប្រធានបទ៖ ប្រាក់ឈ្នួល ទីផ្សារការងារ គម្លាតជំនាញ និងនិន្នាការ ម៉ាក្រូសេដ្ឋកិច្ច ដើម្បីគាំទ្រដល់ការអភិវឌ្ឍគោលនយោបាយពាក់ព័ន្ធ។ ជាមួយនឹងកម្រិតសញ្ញាបត្របណ្ឌិតផ្នែកសេដ្ឋកិច្ចការងារ និងអនុបណ្ឌិតផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុអន្តរជាតិ លោកបណ្ឌិតបានចូលរួមចំណែកយ៉ាងទូលំទូលាយក្នុងការសិក្សាអំពីគោលនយោបាយ ទីផ្សារការងារសកម្ម និងនិន្នាការម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ បទពិសោធន៍ដ៏ច្រើនរបស់លោកបណ្ឌិតក្នុងការស្រាវជ្រាវទីផ្សារការងារ និងការអភិវឌ្ឍជំនាញ បញ្ជាក់ពីការយកចិត្តទុកដាក់របស់លោកបណ្ឌិតក្នុងការលើកកម្ពស់ធនធានមនុស្ស និងការលើកកម្ពស់កំណើនសេដ្ឋកិច្ច ដោយបរិយាប័ន្ននៅក្នុងប្រទេសកម្ពុជា។



**សុខ ឡោ**
តំណាងមកពីសហព័ន្ធនិយោជក
និងសមាគមពាណិជកម្មកម្ពុជា

**លោក សុខ ឡោ** ជានាយកគ្រប់គ្រងក្រុមហ៊ុនច្បាប់ Sok Xing & Hwang និងជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិរបស់ CAMFEBA ជាមួយនឹងបទពិសោធន៍ផ្នែកច្បាប់ រយៈពេល ២០ឆ្នាំ។ លោកមានជំនាញលើការវិនិយោគបរទេស ប្រតិបត្តិការអាជីវកម្ម (mergers and acquisitions) កិច្ចការបទប្បញ្ញត្តិ និងការអនុវត្តច្បាប់នៅកម្ពុជា។ ក្នុងនាមជាតំណាងរបស់ CAMFEBA លោកជា អ្នកជំនាញលើច្បាប់ការងារ និងគោលនយោបាយ។ លោកធ្លាប់បានផ្តល់យោបល់ដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាលអំពីស្តង់ដាការងារ និងគ្រប់គ្រងគម្រោងអន្តរជាតិដែលមានតម្លៃរាប់លានដុល្លារជាមួយអង្គការអន្តរជាតិផ្សេងៗដូចជា EU និង USAID ក្នុងនាមជានាយកប្រតិបត្តិនៃមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល។ លើសពីនេះ លោកក៏បានបង្រៀនជំនាញច្បាប់នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។



**លោកស្រី** Mastumoto Makiko
អ្នកជំនាញការផ្នែកមុខរបរ និងការងារនៃ
អង្គការអន្តរជាតិខាងការងារ ILO

**លោកស្រី Matsumoto Makiko** ជាអ្នកជំនាញផ្នែកមុខរបរ និងការងារ នៃ ILO លើគោលនយោបាយការងារ និងការអភិវឌ្ឍទីផ្សារការងារនៅអាស៊ីបូព៌ា អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក។ ជាមួយនឹងបទពិសោធន៍ ការងារជាងពីរទសវត្សរ៍ លោកស្រីបានធ្វើការងារពាក់ព័ន្ធផលជះនៃសកលភាវូបនីយកម្មការងារ ការងារយុវជន និងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចសម្រាប់ការបង្កើតការងារ។ តាំងពីឆ្នាំ២០១៣ លោកស្រីបានចាប់ផ្តើមការងារនៅទីក្រុងបាងកក ទាក់ទងនឹងកិច្ចសន្ទនាគោលនយោបាយ, អង្កេតកម្លាំងពលកម្ម, និងការកសាងសមត្ថភាពសម្រាប់ការលើកកម្ពស់ការងារ។ លោកស្រីជាអ្នកជំនាញការលើ ការងារយុវជន, សេដ្ឋកិច្ចក្រៅប្រព័ន្ធ, យុទ្ធសាស្ត្រការងារនៅតាមជនបទ និងសមភាពយេនឌ័រក្នុងទីផ្សារការងារ។ លោកស្រី ក៏ធ្លាប់ធ្វើការជាអ្នកស្រាវជ្រាវសេដ្ឋកិច្ចនៅទីក្រុងហ្សឺណែវ និងនៅក្នុងវិស័យឯកជននៅក្នុងទីផ្សាររបស់ជប៉ុនផងដែរ។



**Dr. Abla Safir**
សេដ្ឋវិទូជាន់ខ្ពស់
នៃធនាគារពិភពលោក

**លោកស្រីបណ្ឌិត Abla Safir**គឺជាសេដ្ឋវិទូជាន់ខ្ពស់ផ្នែកគាំពារសង្គមសកលរបស់ធនាគារពិភពលោក ដែលមានមូលដ្ឋាននៅរាជធានីភ្នំពេញ។ លោកស្រីបណ្ឌិត កំពុងដឹកនាំការចូលរួមរបស់ធនាគារលើការគាំពារសង្គម និងលើកម្លាំងពលកម្មនៅកម្ពុជា និងវៀតណាម។ លោកស្រីបណ្ឌិត បានចូលបម្រើការងារអស់រយៈពេល ១៤ឆ្នាំនៅធនាគារពិភពលោក ហើយលោកស្រីបណ្ឌិត បានធ្វើការងារវិភាគលើប្រធានបទ ទីផ្សារការងារ ការធ្វើចំណាកស្រុក ជំនាញ ការគាំពារសង្គម និងការផ្តល់សេវានៅអឺរ៉ុប និងអាស៊ីកណ្តាល ព្រមទាំងមជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង។ លោកស្រីបណ្ឌិត គឺជាសមាជិកស្នូលនៃរបាយការណ៍អភិវឌ្ឍន៍ពិភពលោក ឆ្នាំ២០១៧ “អភិបាលកិច្ចនិងច្បាប់”។ មុនពេលចូលបម្រើការងារជាមួយធនាគារពិភពលោក លោកស្រីបណ្ឌិត ក៏ជាសេដ្ឋវិទូនៅ OECD ដែលជាកន្លែងលោកស្រីបណ្ឌិត បានដឹកនាំកម្មវិធីការងារ ស្តីពីការធ្វើចំណាកស្រុកនៅអាមេរិកកណ្តាល និងអាហ្វ្រិកខាងលិច។ មុនពេលនោះ លោកស្រីបណ្ឌិត បានចូលបម្រើការនៅធនាគារវិនិយោគ BNP Paribas និង Goldman Sachs នៅទីក្រុងឡុងដ៍។ លោកស្រីបណ្ឌិត ទទួលបានសញ្ញាបត្របណ្ឌិតផ្នែកសេដ្ឋកិច្ចពីសាលាសេដ្ឋកិច្ចទីក្រុងប៉ារីស និងសញ្ញាបត្រអនុបណ្ឌិត ពីសាលាធុរកិច្ច HEC និង បញ្ចប់ការសិក្សាពីសាលា ENSAE នៅទីក្រុងប៉ារីស។



**លោក** Shakeel Ahmad
អ្នកតំណាងរងកម្មវិធីអភិវឌ្ឍន៍
សហប្រជាជាតិប្រចាំប្រទេសកម្ពុជា

**លោក Shakeel Ahmad** ជាសេដ្ឋវិទូផ្នែកអភិវឌ្ឍន៍ដែលមានបទពិសោធន៍ជាង ២២ឆ្នាំ ក្នុងការអភិវឌ្ឍអន្តរជាតិ រួមទាំង ១៦ឆ្នាំ ជាមួយ UNDP។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងការអភិវឌ្ឍពីសាលាសេដ្ឋកិច្ច និងវិទ្យាសាស្ត្រនយោបាយទីក្រុងឡុងដ៍ និងមួយទៀតផ្នែកសេដ្ឋកិច្ចកសិកម្មជាមួយនឹងមេដាយមាសពីប្រទេសប៉ាគីស្ថាន។ ពីមុនលោកធ្លាប់បម្រើការជាអ្នកជំនាញការកម្មវិធីប្រចាំប្រទេសនៅស្នាក់ការ UNDP ប្រចាំក្រុងបាងកក ដែលជាកន្លែងលោកទទួលបន្ទុកលើកម្មវិធីនានានៅទូទាំងអាស៊ី និងប៉ាស៊ីហ្វិក។ លោក Shakeel បានកាន់តួនាទីជាអ្នកតំណាងរងស្តីទីរបស់ UNDP នៅស្រីលង្កា ហើយនៅអាហ្វហ្គានីស្ថាន ជាទីប្រឹក្សាគោលនយោបាយ និងនៅប៉ាគីស្ថាន ជាជំនួយការអ្នកតំណាងរងប្រចាំប្រទេស។ បទពិសោធន៍របស់លោកក៏រួមបញ្ចូលការងារជាមួយ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ស្វីស និងគម្រោងអភិវឌ្ឍន៍សហគមន៍នៅក្នុងប្រទេសប៉ាគីស្ថានផងដែរ។ លោក Shakeel បច្ចុប្បន្ននេះ ជាអ្នកតំណាងរងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំប្រទេសកម្ពុជា ចាប់តាំងពីខែកក្កដា ឆ្នាំ២០២៣។

# ៥. ថ្ងៃទី២

## វគ្គទី ៤៖
## “ការអភិវឌ្ឍជំនាញសម្រាប់កសាងកម្លាំងពលកម្មប្រកបដោយភាពប្រកួតប្រជែងនៅកម្ពុជា”

ដើម្បីលើកកម្ពស់ការយល់ដឹងឱ្យបានហ្មត់ចត់អំពីតួនាទីសំខាន់ដែលផលិតភាព និងជំនាញដើរតួក្នុងការសម្រួលដល់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDC) និងការផ្លាស់ប្តូរប្រកបដោយចីរភាព។ គោលបំណងនៃវគ្គនេះ ផ្តោតលើការពិភាក្សាដូចខាងក្រោម៖

- ដើម្បីកំណត់គម្លាតជំនាញសំខាន់ៗដែលរារាំងក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច ព្រមទាំងការបង្កើនផលិតភាព និងការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាពនៅក្នុងទីផ្សារក្នុងតំបន់ និងពិភពលោក។
- ដើម្បីកំណត់ប្រព័ន្ធបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំក្នុងការផ្តល់ឱ្យបុគ្គលនូវជំនាញដែលត្រូវការ ដើម្បីសម្របខ្លួនទៅនឹងការប្រែប្រួលទីផ្សារការងារដែលកំពុងវិវត្ត និងពិនិត្យមើលពីរបៀបដែលគំនិតផ្តួចផ្តើមនៃការរៀនសូត្របន្ត និងពង្រឹងជំនាញ/ការបង្កើនជំនាញ ដើម្បីកែតម្រូវទៅនឹងតម្រូវការផ្លាស់ប្តូរ។
- ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរសេដ្ឋកិច្ច និងលើកកម្ពស់ផលិតភាព ដោយសារវាចាំបាច់ណាស់ក្នុងការពិនិត្យមើលថាតើហេដ្ឋារចនាសម្ព័ន្ធ គោលនយោបាយវិនិយោគ និងគោលនយោបាយពាណិជ្ជកម្មអាចរួមចំណែកដល់សេដ្ឋកិច្ចដែលមានផលិតភាពជាងមុនយ៉ាងដូចម្តេច។
- ដើម្បីលើកទឹកចិត្តដល់ការលើកកម្ពស់យុទ្ធសាស្រ្តសម្រាប់ការផ្លាស់ប្តូរដោយរលូន ដែលពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណ និងការអនុវត្តគោលនយោបាយ និងយន្តការគាំទ្រត្រឹមត្រូវ ដើម្បីស្វែងរកបញ្ហាប្រឈមដែលមកជាមួយការបាត់បង់អត្ថប្រយោជន៍ជាក់លាក់ LDC។
- ដើម្បីជំរុញការសន្ទនាបើកចំហ និងការផ្លាស់ប្តូរចំណេះដឹងរវាងរដ្ឋាភិបាល អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន គឺជាកត្តាសំខាន់សម្រាប់ការផ្លាស់ប្តូរប្រកបដោយជោគជ័យ។

### បទបង្ហាញស្តីពី៖

**«បម្រែបម្រួលទីផ្សារការងារនៅកម្ពុជា៖ តម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្ម»**



**ឯកឧត្តមបណ្ឌិត អ៊ុំ ច័ន្ទមនោ**
ទីប្រឹក្សាអម
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



**លោកស្រី Mary Kent**
អ្នកជំនាញការផ្នែកភាពមានការងារធ្វើ
នៃអង្គការអន្តរជាតិខាងការងារ (ILO)

**«ការបន្សុីប្រព័ន្ធជំនាញសម្រាប់អន្តរកាលប្រកបដោយបរិយាបន្ន និងដំណើរឆ្ពោះទៅកាន់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច»**

### កិច្ចពិភាក្សា៖

**អ្នកសម្របសម្រួល**



ឯកឧត្តម ប៊ុន បូពិត

**ទីប្រឹក្សាអម**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**



ឯកឧត្តមបណ្ឌិត អ៊ុំ ច័ន្ទមនោ

**ទីប្រឹក្សាអម**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**



លោកស្រី Mary Kent

**អ្នកជំនាញការផ្នែកភាពមានការងារធ្វើ**
**នៃអង្គការអន្តរជាតិខាងការងារ (ILO)**



លោកបណ្ឌិត ឆន ឌីណា

**នាយកមជ្ឈមណ្ឌល**
**អភិវឌ្ឍន៍សេដ្ឋកិច្ច និងពាណិជ្ជកម្ម**



លោក ម៉ា សុភា

**មន្ត្រីជាន់ខ្ពស់ផ្នែកសង្គមនៃ**
**ធនាគារអភិវឌ្ឍន៍អាស៊ី**

# វាគ្មិនកិត្តិយស



**ឯកឧត្តមបណ្ឌិត អ៊ុំ ច័ន្ទមនោ**
ទីប្រឹក្សាអម
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ឯកឧត្តមបណ្ឌិត អ៊ុំ ច័ន្ទមនោ** ជាទីប្រឹក្សាអមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ឯកឧត្តមបណ្ឌិត ធ្លាប់ជាអ្នកដឹកនាំ និងជាអ្នកផ្តល់ប្រឹក្សាលើគម្រោងស្រាវជ្រាវជាច្រើនសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ដូចជា Australian Award Cambodia, CAVAC CARITAS Australia , DFAT, JICA, IOM, UNOPS, និង USAID ជាដើម។ ឯកឧត្តមបណ្ឌិត មានបទពិសោធន៍ និងចំណាប់អារម្មណ៍ក្នុងការស្រាវជ្រាវពាក់ព័ន្ធនឹងសេដ្ឋកិច្ចការងារ កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ ឥណទានខ្នាតតូច ការធ្វើចំណាកស្រុក និងប្រាក់បញ្ញើពីបរទេស។



**លោកស្រី** Mary Kent
អ្នកជំនាញការផ្នែកភាពមានការងារធ្វើ
នៃអង្គការអន្តរជាតិខាងការងារ (ILO)

**លោកស្រី ម៉ារី** ជាអ្នកជំនាញថ្នាក់តំបន់ផ្នែកជំនាញ, ភាពមានការងារធ្វើ និង TVET។ លោកស្រី មានបទពិសោធន៍ធ្វើការជាង ២០ឆ្នាំ ជាមួយរាជរដ្ឋាភិបាល គ្រឹះស្ថាន TVET, ឧស្សាហកម្ម និងតំណាងកម្មករនិយោជិត។ លោកស្រី បានចូលរួមចំណែក ក្នុងការអភិវឌ្ឍគោលនយោបាយ កម្មវិធីធំៗ និងភាពជាដៃគូអន្តរជាតិនៅ ១៦ ប្រទេស រួមមាន ចក្រភពអង់គ្លេស ប្រទេសចិន និងអាហ្វ្រិកខាងត្បូង។ មុនពេលចូលបម្រើការងារនៅ ILO លោកស្រីបានបម្រើការជានាយករងនៅមហាវិទ្យាល័យ Cardiff និង Vale ដោយបានប្រែក្លាយទៅជាស្ថាប័នវិជ្ជាជីវៈដ៏ធំបំផុតមួយក្នុងចំណោមស្ថាប័នផ្សេងទៀតនៅចក្រភពអង់គ្លេស។ លោកស្រីក៏ធ្លាប់បានធ្វើការជានាយកនៅ Hays Plc ផ្តោតលើបញ្ហាកង្វះជំនាញក្នុងវិស័យអាទិភាព។ លោកស្រី មានជំនាញ ដូចជា ការបញ្ជ្រាបយេនឌ័រ ពិការភាព និងគោលនយោបាយ ឧស្សាហកម្មបៃតង ហើយក៏បានទទួលបានសញ្ញាបត្រ ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងធុរកិច្ច។



**លោកបណ្ឌិត ឆន ឌីណា**
នាយកមជ្ឈមណ្ឌល
អភិវឌ្ឍន៍សេដ្ឋកិច្ច និងពាណិជ្ជកម្ម

**លោកបណ្ឌិត ឆន ឌីណា** បច្ចុប្បន្នជានាយកមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ចអភិវឌ្ឍន៍ និងពាណិជ្ជកម្មនៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)។ លោកបណ្ឌិតជាសេដ្ឋវិទូជ្រើសរើសដោយ គណៈកម្មការសហភាពអឺរ៉ុប (European Commission) ក្រោមកម្មវិធី Marie Skłodowska-Curie Actions ទៅកាន់កិច្ចប្រជុំ The 7th Lindau Nobel Laureate Meetings នៅក្នុងប្រទេសអាល្លឺម៉ង់។ លោកបណ្ឌិតបានបញ្ចប់ការស្រាវជ្រាវថ្នាក់ក្រោយបណ្ឌិតនៅសាកលវិទ្យាល័យ Lausanne នៃប្រទេសស្វីស និងបានបញ្ចប់ថ្នាក់បណ្ឌិត ផ្នែកសេដ្ឋកិច្ច ពីសាកលវិទ្យាល័យ Bordeaux នៃប្រទេសបារាំង ហើយបានបង្រៀនមុខជំនាញ Econometrics និង Statistics នៅទីនោះផងដែរ។



**លោក ម៉ា សុភា**
មន្ត្រីជាន់ខ្ពស់ផ្នែកសង្គមនៃ
ធនាគារអភិវឌ្ឍន៍អាស៊ី

**លោក ម៉ា សុភា** បានចូលបម្រើការនៅធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងឆ្នាំ២០០៣ និងបម្រើការជាមន្ត្រីគម្រោងជាន់ខ្ពស់ (ការអប់រំ និងជំនាញ) និងចូលរួមជាអ្នកដឹកនាំបេសកកម្មសម្រាប់គម្រោង និងកម្មវិធីក្នុងវិស័យអប់រំ និងជំនាញ។ មុនពេលបម្រើការងារជាមួយ ADB លោក ម៉ា សុភា ធ្លាប់ជាអ្នកគ្រប់គ្រងកម្មវិធីជាតិ និងជាប្រធានទីប្រឹក្សាបច្ចេកទេសសម្រាប់អង្គការអន្តរជាតិខាងការងារ (ILO) ពីឆ្នាំ១៩៩៥ ដោយបម្រើការនៅក្នុងប្រទេសកម្ពុជា និងបង់ក្លាដែស (២០០៩-២០១១)។



**ឯកឧត្តម ប៊ុន បូពិត**
ទីប្រឹក្សាអម
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ឯកឧត្តម ប៊ុន បូពិត** ជាទីប្រឹក្សាអមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលក្នុងនោះ ឯកឧត្តមចូលរួម ក្នុងការសិក្សាលើគម្រោងផ្សេងៗ ដើម្បីលើកស្ទួយគោលនយោបាយ និងការអភិវឌ្ឍទីផ្សារការងារនៅក្នុងប្រទេសកម្ពុជា។ ឯកឧត្តម កំពុងបន្តសិក្សាថ្នាក់បណ្ឌិតផ្នែកការសិក្សាអន្តរជាតិនៅសាកលវិទ្យាល័យវ៉ាសេដា ប្រទេសជប៉ុន ហើយបានទទួលសញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យអន្តរជាតិ នៃប្រទេសជប៉ុន។ ឯកឧត្តម មានចំណាប់អារម្មណ៍ចំពោះ ការសិក្សាស្រាវជ្រាវទៅលើថាមវន្តនៃទីផ្សារការងារ ការវិនិយោគដោយផ្ទាល់ពីបរទេស និង គោលនយោបាយសេដ្ឋកិច្ច។ បន្ថែមពីនេះ ការរួមចំណែកក្នុងផ្នែកសិក្សាស្រាវជ្រាវរបស់ឯកឧត្តម រួមមាន៖ អត្ថបទដែលត្រូវបានបោះពុម្ពផ្សាយក្នុងទិនានុប្បវត្តិសមាហរណកម្មសេដ្ឋកិច្ច។

## វគ្គទី ៥៖
## “ការពង្រឹងប្រព័ន្ធសន្តិសុខសង្គម ដើម្បីលើកកម្ពស់ភាពធន់ នៃទីផ្សារការងារ និងជំរុញការចូលរួមនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ”

វគ្គនេះមានគោលបំណងស្វែងយល់អំពីតួនាទីនៃប្រព័ន្ធសន្តិសុខសង្គម និងស្ថាប័នទីផ្សារការងារក្នុងការចូលរួមចំណែកក្នុងស្ថិរភាពសេដ្ឋកិច្ច កិច្ចគាំពារកម្មករ និយោជិត និងប្រសិទ្ធភាពទីផ្សារការងាររបស់កម្ពុជា។ អ្នកជំនាញ អ្នកបង្កើតគោលនយោបាយ អ្នកស្រាវជ្រាវ និងអ្នកធ្វើការងារពាក់ព័ន្ធនឹងវិស័យនេះ នឹងពិភាក្សាអំពីបញ្ហាប្រឈម និងឱកាសពាក់ព័ន្ធនឹងស្ថាប័នទីផ្សារការងារ និងប្រព័ន្ធសន្តិសុខសង្គម ជាពិសេសនៅក្នុងបរិបទនៃការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា។ វគ្គនេះ នឹងវាយតម្លៃប្រសិទ្ធភាពនៃប្រព័ន្ធនេះ ចែករំលែកការអនុវត្តល្អៗ និងស្វែងរកកំណែទម្រង់ដែលមានសក្តានុពលក្នុងគោលបំណងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងការកែលម្អកិច្ចគាំពារសង្គម សម្រាប់កម្លាំងពលកម្មរបស់ប្រទេស។

វគ្គនេះ មានសារៈសំខាន់មួយចំនួនដូចខាងក្រោម៖

- ការយល់ដឹងអំពីតួនាទីរបស់ស្ថាប័ន៖ វគ្គនេះនឹងផ្តល់ជាវេទិកាមួយដើម្បីពិភាក្សាអំពីតួនាទី និងការទទួលខុសត្រូវជាក់លាក់របស់ស្ថាប័នសន្តិសុខសង្គម និងទីផ្សារការងារនៅក្នុងប្រទេសកម្ពុជា ដោយបញ្ជាក់ពីអាណត្តិ និងមុខងាររបស់ស្ថាប័ននេះ។
- ការវាយតម្លៃប្រសិទ្ធភាព៖ វគ្គនេះនឹងពិភាក្សាអំពីវិធីសាស្ត្រនៃការចូលរួមចំណែកប្រកបដោយប្រសិទ្ធភាពរបស់ស្ថាប័នទីផ្សារការងារ និងប្រព័ន្ធសន្តិសុខសង្គម ក្នុងការកាត់បន្ថយវិសមភាព ការជំរុញផលិតភាព និងការលើកកម្ពស់សុខុមាលភាពរបស់កម្មករនិយោជិត។
- ការកំណត់បញ្ហាប្រឈម៖ ដោយសារកម្លាំងពលកម្មវ័យក្មេងរបស់កម្ពុជាកំពុងកើនឡើង វាពិតជាមានសារៈសំខាន់ណាស់ក្នុងការកំណត់បញ្ហាប្រឈម និងសំណើកំណែទម្រង់ដែលស្របតាមស្តង់ដារអន្តរជាតិ និងគោលដៅអភិវឌ្ឍន៍របស់ប្រទេស។
- ស្វែងយល់ពីឱកាស៖ កិច្ចពិភាក្សាក្នុងវគ្គនេះ នឹងស្វែងយល់ពីឱកាសសម្រាប់ធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ស្ថាប័នសន្តិសុខសង្គម និងទីផ្សារការងារ ដូចជាកំណែទម្រង់គោលនយោបាយ ការពង្រឹងស្ថាប័ន និងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ។
- ផលប៉ះពាល់គោលនយោបាយ៖ ការពិភាក្សានឹងផ្តល់ព័ត៌មានដ៏មានតម្លៃបន្ថែម ដល់ធ្វើឱ្យអ្នកបង្កើតគោលនយោបាយ សម្រាប់ការបង្កើតការកាំពារសង្គមប្រកបដោយប្រសិទ្ធភាព និងគោលនយោបាយទីផ្សារការងារផ្សេងទៀត។

### បទបង្ហាញស្តីពី៖

«ការអភិវឌ្ឍថ្មីៗ និងយុទ្ធសាស្ត្រក្នុងការពង្រីករបបសន្តិសុខសង្គមឆ្ពោះទៅការដាក់ឱ្យអនុវត្តរបបនិកម្មភាព»



ឯកឧត្តម យុន ចាន់ណារិទ្ធ
អគ្គនាយករង
នៃបេឡាជាតិសន្តិសុខសង្គម



លោក Jie Yu Koh
អ្នកគ្រប់គ្រងកម្មវិធីគាំពារសង្គម នៃអង្គការអន្តរជាតិខាងការងារ (ILO)

«ការជំរុញការចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងការពង្រីកវិសាលភាពរបបសន្តិសុខសង្គម ដើម្បីឈានទៅសម្រេចបានការងារសមរម្យនៅកម្ពុជា»

### អ្នកសម្របសម្រួល

### កិច្ចពិភាក្សា៖



ឯកឧត្តមបណ្ឌិត ខឹម បូរិន
ទីប្រឹក្សាអម
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



ឯកឧត្តម យុន ចាន់ណារិទ្ធ
អគ្គនាយករងនៃ
បេឡាជាតិសន្តិសុខសង្គម



លោក គង់ អាទិត្យ
ប្រធានសហភាពការងារកម្ពុជា



លោក ធឿង ធានី
ប្រធានស្តីទីនាយកដ្ឋានគាំទ្រប្រតិបត្តិការ
នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារ
សង្គម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



លោក Jie Yu Koh
អ្នកគ្រប់គ្រងកម្មវិធីគាំពារសង្គម
នៃអង្គការអន្តរជាតិ
ខាងការងារ (ILO)

# ខាគ្និនកិត្តិយស



**ឯកឧត្តម ឃុន ចាន់ណារិទ្ធ**
អគ្គនាយករងនៃ
បេឡាជាតិសន្តិសុខសង្គម

**ឯកឧត្តម ឃុន ចាន់ណារិទ្ធ** ជាអគ្គនាយករងនៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៅកម្ពុជា ដោយមានបទពិសោធន៍ជាង ១៤ ឆ្នាំ ក្នុងតួនាទីថ្នាក់ដឹកនាំក្នុងការរៀបចំគោលនយោបាយ ការស្រាវជ្រាវ និងការគ្រប់គ្រងប្រតិបត្តិការអាជីវកម្មនិងគម្រោងវិនិយោគ។ ឯកឧត្តម បានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍ វិស័យការងារនិងសេវាការងារសាធារណៈ ការគ្របដណ្តប់សុខភាពជាសាកល កម្មវិធីផ្ទេរសាច់ប្រាក់ និងយុទ្ធសាស្ត្រវិស័យសន្តិសុខសង្គមនៅកម្ពុជា។ ឯកឧត្តម ឃុន ចាន់ណារិទ្ធ មានសញ្ញាបត្រជាន់ខ្ពស់ជំនាញគ្រប់គ្រង និងកម្មសិទ្ធបញ្ញាពីសាកលវិទ្យាល័យលីយ៉ុង២(បារាំង) និងមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ណ័រថាំប្រៀ Northumbria Business School (ចក្រភពអង់គ្លេស)។ កាលជាអតីតសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ ឯកឧត្តមបានចូលរួមក្នុងការស្រាវជ្រាវអំពី ពាណិជ្ជកម្មអន្តរជាតិ វិស័យការងារនិងសេវាការងារសាធារណៈ និងវិស័យសន្តិសុខសង្គម ដោយផ្តោតលើការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រប្រកបដោយចីរភាពក្នុងវិស័យសន្តិសុខសង្គម។



**លោក ចឿង ឆានី**
ប្រធានស្តីទីនាយកដ្ឋានគាំទ្រប្រតិបត្តិការ
នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**លោក ចឿង ឆានី** ជាប្រធានស្តីទីនៃនាយកដ្ឋានគាំទ្រប្រតិបត្តិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលក្នុងនោះលោកបានទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយសង្គមពីសាលា KDI School of Public Policy and Management នៅសាធារណៈរដ្ឋកូរ៉េ។ លោកបានចូលបម្រើការងារនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម (NSPC) ក្នុងឆ្នាំ២០២០ ដែលគាំទ្រដល់ការអភិវឌ្ឍន៍នូវកម្មវិធីជំនួយសង្គម។ មុនចូលបម្រើការងារនៅ NSPC លោកបានធ្វើការជាសេដ្ឋវិទូវ័យក្មេងនៅអគ្គនាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលលោកទទួលបន្ទុកលើការព្យាករនិងតាមដានចំណូល និងចំណាយ។ ជាមួយនឹងតួនាទីបច្ចុប្បន្ន លោកជានាថា ការចេញគោលនយោបាយគាំពារសង្គមអាចត្រូវបានគាំទ្រដោយកត្តាផ្តល់លទ្ធភាពផ្សេងៗ ដែលមិនកំណត់តែចំពោះហិរញ្ញប្បទាន ការទំនាក់ទំនង យន្តការបណ្តឹងផ្សេងៗទៀត។



**លោក គង់ អាទិត្យ**
ប្រធានសហភាពការងារកម្ពុជា

**លោក គង់ អាទិត្យ** ជាប្រធានសហភាពការងារកម្ពុជា (CLC)។ លោក ជាតំណាងកម្មករ និយោជិត តាំងពីឆ្នាំ១៩៩៨ ពីកម្រិតរោងចក្រ សហព័ន្ធ និងសហភាពសហជីព។ លោកធ្លាប់ត្រូវបានបោះឆ្នោតជា សហប្រធាន នៃ IndustriAll តំណាងវិស័យវាយនភណ្ឌ កាត់ដេរ ស្បែកជើង និងផលិតផលពីស្បែក នៅឆ្នាំ២០១៦។ ក្នុងនាមជាតំណាងកម្មករនិយោជិត លោកបានបម្រើការងារជាច្រើនពាក់ព័ន្ធនឹងកិច្ចការសហប្រតិបត្តិការអន្តរជាតិផ្នែកតស៊ូមតិ និងដោះស្រាយវិវាទការងារ។



**លោក** Jie Yu Koh
អ្នកគ្រប់គ្រងកម្មវិធីគាំពារសង្គម នៃ
អង្គការអន្តរជាតិខាងការងារ (ILO)

**លោក Jie Yu Koh** ជាអ្នកគ្រប់គ្រងកម្មវិធីកិច្ចគាំពារសង្គមនៃអង្គការ ILO នៅកម្ពុជា ហើយបម្រើការងារជាជនបង្គោលសម្រាប់គាំពារសង្គម និងជាទីប្រឹក្សាបច្ចេកទេសស្ថាប័នរាជរដ្ឋាភិបាល និយោជក និងសហជីព។ ការងាររបស់លោកផ្តោតលើការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅប្រទេសកម្ពុជា តាមរយៈការទទួលយកបច្ចេកវិទ្យា ការពង្រីកការគ្របដណ្តប់ និងធ្វើឱ្យប្រសើរឡើងនូវអត្ថប្រយោជន៍ និងពង្រឹងគណនេយ្យភាពតាមរយៈការត្រួតពិនិត្យលើគោលនយោបាយ និងការអភិវឌ្ឍយុទ្ធសាស្ត្រ។ លោកជាអ្នកគាំទ្រការអភិវឌ្ឍ សិទ្ធិមូលដ្ឋាន ការតស៊ូមតិ ដើម្បីកាត់បន្ថយការកើនឡើងភាពក្រីក្រ និងកាត់បន្ថយវិសមភាពជាប្រព័ន្ធ តាមរយៈការបង្កើតទម្រង់សេដ្ឋកិច្ច។ កន្លងមកលោក ជាអ្នកប្រឹក្សាផ្នែកវិភាគទិន្នន័យ និងបដិវត្ត។ លោក Jie Yu Koh ទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកគោលនយោបាយសាធារណៈ ពីសាកលវិទ្យាល័យ UNU-MERIT និង Maastricht ។



**ឯកឧត្តមបណ្ឌិត ខឹម បូរិន**
ទីប្រឹក្សាអម
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ឯកឧត្តមបណ្ឌិត ខឹម បូរិន** ជាទីប្រឹក្សាអមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលទទួលបន្ទុកលើកិច្ចការងារគ្រប់គ្រង និងវិភាគទិន្នន័យ រៀបចំផ្ទាំងរបាយការណ៍ វិភាគនិន្នាការសេដ្ឋកិច្ច និងទីផ្សារការងារ និងចូលរួមចំណែកក្នុងការកសាង គោលនយោបាយដោយឈរលើទឡ្ហីករណ៍។ នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តមបណ្ឌិត ដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំ ផលិត ទាញសេចក្តីសន្និដ្ឋានពីទិន្នន័យដើម្បីសម្រួចយុទ្ធសាស្ត្រ និងគោលនយោបាយ សំដៅធ្វើឱ្យប្រសើរឡើងនូវទីផ្សារការងារ របបសន្តិសុខសង្គម និងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈក្នុងព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមបណ្ឌិត ខឹម បូរិន ទទួលបានសញ្ញាបត្រថ្នាក់បណ្ឌិត ជំនាញវិទ្យាសាស្ត្រកសិកម្ម ពីសាកលវិទ្យាល័យឃ្យូស៊ូ ប្រទេសជប៉ុន ដែលការសិក្សានេះបានផ្តល់ជូនមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការស្រាវជ្រាវ និងការអភិវឌ្ឍសមត្ថភាពវិភាគប្រកបដោយភាពច្បាស់លាស់។ ចំណេះជំនាញនេះបានបន្តគាំទ្រលោកក្នុងការសិក្សាស្រាវជ្រាវ វិភាគនិន្នាការសេដ្ឋកិច្ច ទីផ្សារការងារ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងបរិបទកម្លាំងពលកម្ម និងចូលរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

# សុន្ទរកថាបិទ



## ឯកឧត្តម គួច សុមាន

រដ្ឋលេខាធិការក្រសួងការងារ
និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ឯកឧត្តម គួច សុមាន ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា តែងតាំងជារដ្ឋលេខាធិការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅខែសីហា ឆ្នាំ២០២៣។ ឯកឧត្តម គឺជាថ្នាក់ដឹកនាំវ័យក្មេងដ៏មានជំនាញបច្ចេកទេសមួយរូប។ ឯកឧត្តម មានបទពិសោធជាមន្ត្រីរាជការអស់រយៈពេលជាង១០ឆ្នាំ និងធ្លាប់មានតួនាទីជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា, អនុប្រធាននៃទីភ្នាក់ងារជាតិមុខរបរ និងការងារ និងជាទីប្រឹក្សាអមក្រសួងផងដែរ។ ឯកឧត្តម មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ និងលើកកម្ពស់សេវាការងារសាធារណៈ, ប្រព័ន្ធព័ត៌មានទីផ្សារការងារ, សន្តិសុខសង្គម និងប្រាក់ឈ្នួលអប្បបរមានៅក្នុងប្រទេសកម្ពុជា។ ឯកឧត្តម បានធ្វើការសិក្សាស្រាវជ្រាវ និងបោះពុម្ពផ្សាយយ៉ាងទូលំទូលាយ ទាក់ទងនឹងប្រធានបទសេដ្ឋកិច្ចការងារ ដែលផ្តោតសំខាន់ទៅលើគម្លាតជំនាញ, កង្វះជំនាញ, ការអភិវឌ្ឍជំនាញសម្រាប់ពិពិធកម្មសេដ្ឋកិច្ច, ទេសន្តរប្រវេសន៍ និងប្រាក់បញ្ញើ។ ឯកឧត្តម ក៏បានចូលរួមរៀបចំតាក់តែង គោលនយោបាយថ្នាក់ជាតិមួយចំនួនដូចជា គោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារ, គោលនយោបាយជាតិ ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងគោលនយោបាយទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា។ ឯកឧត្តម កំពុងបន្តការសិក្សាថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យណាហ្គូយ៉ា (Nagoya University) ប្រទេសជប៉ុន លើជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍។ ឯកឧត្តម បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែក Applied Labor Economics for Development ពីសាកលវិទ្យាល័យស្យង់ប៉ូ ប្រទេសបារាំង និងសាកលវិទ្យាល័យទូរិន ប្រទេសអ៊ីតាលី និងអនុបណ្ឌិតផ្នែកគ្រប់គ្រង ពីសាលាគ្រប់គ្រងអូដិនសៀ ណាន (Audencia Nantes School of Management) ប្រទេសបារាំង ផងដែរ។




# NATIONAL LABOUR ECONOMIC CONFERENCE 2024

## ECONOMIC AND EMPLOYMENT RECOVERY AND THE PATH TO LDC GRADUATION

UNDP | International Labour Organization | DEY DECENT EMPLOYMENT FOR YOUTH IN CAMBODIA | Swiss Agency for Development and Cooperation SDC | TAFTAC | CGTI

Sofitel Phnom Penh Phokeethra, Phnom Penh, Cambodia

11-12 December 2024

# CONTENT





1. Introduction

2. Objectives

3. Agenda

4. Day 1

5. Day 2

# 1. Introduction

## 1.Introduction

